# សិទ្ធិកុមារ និង បម្រែបម្រួលអាកាសធាតុ

<u>**មតិទូទៅលេខ26:**</u>

**បរិស្ថានស្អាត និងអាកាសធាតុដែលមានសុវត្ថិភាពមានសារៈសំខាន់សម្រាប់សិទ្ធិកុមារ។ រដ្ឋាភិបាលគួរតែពិចារណាអំពីសិទ្ធិរបស់កុមារនៅក្នុងការសម្រេចចិត្តទាំងអស់ដែលធ្វើឡើងអំពីការប្រែប្រួលអាកាសធាតុ និងពិចារណាអំពីការប្រែប្រួលអាកាសធាតុនៅក្នុងការសម្រេចចិត្តទាំងអស់ដែលត្រូវបានធ្វើឡើងអំពីកុមារ។**

## សំឡេងរបស់កុមារពីប្រទេសកម្ពុជា

អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា បានរៀបចំការពិគ្រោះយោបល់ជាច្រើនជាមួយកុមារជាសមាជិកនៃបណ្តាញដឹកនាំកុមារ និងយុវជន (ទីនះ) ដើម្បីគាំទ្រដល់ការចូលរួមរបស់ពួកគេក្នុងការសម្រេចចិត្តអំពីអាកាសធាតុ។



### បញ្ហាផ្សេងៗដែលប្រឈមដោយកុមារ

- **ការបំពុលខ្យល់ និងទឹក**
- **រលកកំដៅ ភ្លៀងធ្លាក់ខ្លាំង ខ្យល់ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួត**
- ការបាត់បង់ជីវចម្រុះ និងធនធានធម្មជាតិ
- ការកាប់បំផ្លាញព្រៃឈើ

‘ទោះបីជាមានការដាំដុះឡើងវិញក៏ដោយ ក៏វាត្រូវការពេលវេលាសម្រាប់ការលូតលាស់ដែរ’

- ការធ្វើកសិកម្មនានាដែលបង្កគ្រោះថ្នាក់
- ការចោលកាកសំណល់មិនត្រឹមត្រូវ និងការប្រើប្រាស់ផ្លាស្ទិចច្រើនពេក

‘មានការដុតសំរាមគ្រប់ទីកន្លែង’

- រលកកំដៅ ភ្លៀងធ្លាក់ខ្លាំង ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួត
- គ្មានទីជម្រកដែលមានសុវត្ថិភាពពេលមានទឹកជំនន់
- ការយល់ដឹង និងការត្រៀមខ្លួនសម្រាប់គ្រោះអាសន្នទាក់ទងនឹងអាកាសធាតុនៅមានកម្រិត
- មិនត្រូវបានបញ្ចូលក្នុងផែនការអភិវឌ្ឍន៍នានាក្នុងមូលដ្ឋាន
- ការអប់រំអំពីអាកាសធាតុ និងយុទ្ធនាការការយល់ដឹងដោយផ្តោតផលប៉ះពាល់លើកុមារនៅមានកម្រិត

## តើបញ្ហាទាំងនេះផ្ដល់ប៉ះពាល់ដល់កុមារយ៉ាងដូចម្ដេចខ្លះ?

**សុខភាពផ្នែកផ្លូវកាយ និងផ្លូវចិត្តរបស់យើងត្រូវបានប៉ះពាល់។ យើងមានបញ្ហាសួតនៅពេលដកដង្ហើមខ្យល់ដែលមានជាតិពុល ប៉ុន្តែវាក៏បណ្ដាលមកពីកង្វះអាហារដែរ ដោយសារការប្រមូលផលមិនល្អ។**

**គ្រួសារមានការព្រួយបារម្ភអំពីប្រាក់ចំណូល និងរបៀបរ៉ាប់រងការចំណាយ។ ពួកគេមិនអាចជួយដល់ការសិក្សារបស់កូនៗបានទេ។ កុមារខ្លះឈប់រៀន ហើយចាប់ផ្តើមធ្វើការដើម្បីផ្គត់ផ្គង់គ្រួសារ។**

**ឪពុកម្ដាយខ្លះត្រូវចំណាកស្រុកទៅកន្លែងផ្សេង ឬក្រៅប្រទេសដើម្បីស្វែងរកការងារធ្វើ។**

សាលារៀននានានៅឆ្ងាយ ផ្លូវមិនមានសុវត្ថិភាព និងកាន់តែគ្រោះថ្នាក់នៅពេលមានដែលទឹកជំនន់។

ថ្នាក់រៀនជាច្រើនមិនមានភាពធន់ទៅនឹងអាកាសធាតុ។ យើងមានអារម្មណ៍ថាអស់កម្លាំង និងមិនអាចផ្តោតអារម្មណ៍លើការសិក្សា ជាពិសេសនៅពេលរសៀល។ យើងមិនអាចរៀនបានទេ
ការសិក្សារបស់យើងមានកម្រិតទាប។

ខ្ញុំមានការបារម្ភថា កូនចៅជំនាន់ក្រោយនឹងលែងទទួលបានប្រយោជន៍ពីធម្មជាតិទៀតហើយ។ ខ្ញុំមិនចង់ឃើញទេ ការកាប់បំផ្លាញព្រៃឈើ ឬកង្វះទឹកភ្លៀងទេ។ ផ្ទះខ្ញុំឥឡូវអត់មានទឹកប្រើប្រាស់ទេ។



## ការស្នើសុំរបស់កុមារ

- ការពារដីសហគមន៍ និងព្រៃឈើពីការធ្វើសម្បទានពាណិជ្ជកម្ម (ការជួល)។
- ផ្សព្វផ្សាយព័ត៌មានអំពីអាកាសធាតុ និងគ្រោះមហន្តរាយក្នុង (ភាសារក្នុងស្រុក) ទម្រង់ដែលងាយស្រួលសម្រាប់កុមារ ដូចជាការប្រាប់ពីរឿងរ៉ាវ និងព្រឹត្តិការណ៍សហគមន៍។
- សាងសង់សាលារៀនដែលមានភាពធន់នឹងអាកាសធាតុ និងហេដ្ឋារចនាសម្ព័ន្ធដែលមានសុវត្ថិភាព។
- ផ្សព្វផ្សាយខ្លឹមសារអប់រំដែលពាក់ព័ន្ធនានាស្តីពីការប្រែប្រួលអាកាសធាតុ និងការអនុវត្តប្រកបដោយនិរន្តរភាពជាភាសក្នុងតំបន់។
- អនុញ្ញាតឱ្យក្លឹបកុមារ និងយុវជនចូលរួមក្នុងសកម្មភាពទាក់ទងនឹងអាកាសធាតុ និងការយល់ដឹងជាសាធារណៈ។
- បង្កើតវេទិកាសម្រាប់កុមារអាចនិយាយនៅក្នុងកិច្ចប្រជុំថ្នាក់ឃុំ ឬសង្កាត់អំពីបញ្ហាអាកាសធាតុ។
- ធានាបាននូវការទុកដាក់បានត្រឹមត្រូវ និងអនាម័យនៃរាល់កាកសំណល់។

ខែកក្កដា ឆ្នាំ 2025